ADB

# មហាអនុតំបន់ទន្លេមេគង្គ
# កិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន (CBTA)
# ការបើកដំណើរការឡើងវិញឆ្នាំ ២០២៤
# «ដំណាក់កាលប្រមូលផលដំហានដំបូង ( EARLY HARVEST )»

## មេរៀនទី១ ( B ) - បញ្ហាអនុលោមភាព

បង្កើតឡើងក្រោមគម្រោងជំនួយបច្ចេកទេសលេខ TA 6579-REG ៖ ការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន «ដំណាក់កាលប្រមូលផលដំហានដំបូង» ក្នុងមហាអនុតំបន់ទន្លេមេគង្គ តាមរយៈសហហិរញ្ញប្បទាន ដោយ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស

# សេចក្តីផ្តើម

- អនុស្សារណៈយោគយល់ "Early Harvest" ផ្អែកតាមការប្តេជ្ញាធ្វើឡើងក្រោមកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែននៃមហាអនុតំបន់ទន្លេមេគង្គ (CBTA)
- បញ្ហាអនុលោមភាព ស្ថិតក្រោមយុត្តាធិការនៃប្រទេស "កំណើត" ឬប្រទេស "ម្ចាស់ផ្ទះ"
- ប្រទេស "**កំណើត**" គឺជាប្រទេសនៃមហាអនុតំបន់ទន្លេមេគង្គ ដែលប្រតិបត្តិករដឹកជញ្ជូនបានចុះបញ្ជី និងជាទីតាំងគោលដែលយានដឹកជញ្ជូនស្ថិតនៅ
- ប្រទេស "**ម្ចាស់ផ្ទះ**" សំដៅដល់បណ្តាប្រទេសនៃមហាអនុតំបន់ទន្លេមេគង្គផ្សេងទៀត ដែលប្រតិបត្តិការដឹកជញ្ជូន បានឆ្លងកាត់ ក្រោមកិច្ចព្រមព្រៀង CBTA 'Early Harvest'

# អនុលោមភាព ក្នុងប្រទេស "កំណើត"

- ប្រទេសនៃមហាអនុតំបន់ទន្លេមេគង្គ (GMS) នីមួយៗ អាចផ្តល់ជូនលិខិតអនុញ្ញាត (Permit) និងឯកសារអនុញ្ញាតិឱ្យយានយន្តចូលបណ្តោះអាសន្ន (TADs) នៃការដឹកជញ្ជូនតាមផ្លូវថ្នល់(ដែលអាចចេញចូលច្រើនដង)ក្នុងប្រទេស GMS រហូតដល់ចំនួន ៥០០ ច្បាប់ ។ ដើម្បីទទួលបាន Permits និងឯកសារ TADs សម្រាប់យានយន្ត បេក្ខជនត្រូវ៖

1. ចុះបញ្ជីជាប្រតិបត្តិករដឹកជញ្ជូនអន្តរជាតិ នៅក្នុងប្រទេសកំណើតរបស់ពួកគេ និងបំពេញលក្ខខណ្ឌដូចមានក្នុងប្រការ ២,៣,៤,៥ និង ៦ នៃឧបសម្ព័ន្ធ ៩ នៃ CBTA
2. មានចំណែកហ៊ុនយ៉ាងតិច ៥១% និងដឹកនាំដោយពលរដ្ឋនៃប្រទេសកំណើតនោះ
3. ពុំមានជាប់ទោស ឬទណ្ឌកម្មពីប្រទេសកំណើត ហើយត្រូវមានកំណត់ត្រាផ្លូវច្បាប់ស្អាតស្អំ និងមិនមានជាប់ពាក់ព័ន្ធភាពក្ស័យធនបច្ចុប្បន្ន និង/ឬ មិនត្រូវបានដោះស្រាយ
4. មានសមត្ថកិច្ចធ្វើប្រតិបត្តិការប្រកបដោយវិជ្ជាជីវៈ (ពោលគឺ គោរពតាមច្បាប់បញ្ញត្តិ ការគ្រប់គ្រងប្រតិបត្តិបញ្ហាសុវត្ថិភាពតាមផ្លូវថ្នល់ និងលក្ខណៈបច្ចេកទេសដែលជាប់ទាក់ទងនឹងអាជីវកម្មដឹកជញ្ជូនតាមផ្លូវថ្នល់នៅតាមបណ្តាប្រទេសដែលគ្រោងនឹងឆ្លងកាត់)
5. មានធានធានហិរញ្ញវត្ថុគ្រប់គ្រាន់ និងមានធានារ៉ាប់រងផ្នែកហិរញ្ញវត្ថុ ទៅលើទំនួលខុសត្រូវកិច្ចសន្យា និង/ឬ ប្រតិបត្តិការ

# អនុលោមភាព ក្នុងប្រទេស "កំណើត" (បន្ត)

- ប្រតិបត្តិករទាំងឡាយ ត្រូវធានាថា អ្នកបើកបរ និងយានយន្តរបស់ពួកគេ បំពេញតាមលក្ខខណ្ឌស្នើសុំ ដូចមានចែងក្នុងប្រការ ១១-១៨ នៃអត្ថបទគោល CBTA ដូចខាងក្រោម៖
  a) ប័ណ្ណចុះបញ្ជីយានយន្ត
  b) លក្ខខណ្ឌបច្ចេកទេសយានយន្ត (បទដ្ឋានសុវត្ថិភាព និងការបំភាយឧស្ម័ន)
  c) មានវិញ្ញាបនបត្រត្រួតពិនិត្យលក្ខណៈបច្ចេកទេសដែលមានសុពលភាព
  d) ធានារ៉ាប់រងយានយន្តពីភាគីទីបីជាកំហិត (ពេញមួយរយៈពេលធ្វើដំណើរ)
  e) លិខិតអនុញ្ញាតឱ្យបើកបរ
- ម្ចាស់/ប្រតិបត្តិករ យានយន្ត ត្រូវចុះហត្ថលេខាលើកិច្ចការ ដែលមានភ្ជាប់នៅលើទំព័រទី ៥ នៃឯកសារ TAD របស់យានយន្តនីមួយៗ និងត្រូវយល់ច្បាស់ពីលក្ខន្តិកៈនៃការប្រើប្រាស់ដែលមានភ្ជាប់។

# អនុលោមភាពក្នុងប្រទេស “ម្ចាស់ផ្ទះ”

- យានយន្តត្រូវភ្ជាប់មកជាមួយគ្រប់ពេលនូវលិខិតអនុញ្ញាត (Permit) និងឯកសារ TAD ច្បាប់ដើម ដែលចេញជូនដោយអាជ្ញាធរមានសមត្ថកិច្ច នៅក្នុងប្រទេសកំណើតរបស់ពួកគេ។
- TAD គឺជា ‵លិខិតឆ្លងដែន′ របស់យានយន្ត ហើយត្រូវចុះហត្ថលេខា ឬបោះត្រា និងចុះកាលបរិច្ឆេទ នៅតាមច្រកព្រំដែន ដោយមន្ត្រីគយនៃប្រទេសជាម្ចាស់ផ្ទះ នៅរាល់ពេលចេញ និងចូលក្នុងប្រទេសនោះ។
- មិនមានការកំណត់លើចំនួនដងនៃការធ្វើដំណើរឡើយ ប៉ុន្តែពុំអនុញ្ញាតឱ្យយានយន្តស្ថិតនៅក្នុងប្រទេសជាម្ចាស់ផ្ទះ លើសពីរយៈពេល ៣០ថ្ងៃ ក្នុងការធ្វើដំណើរមួយដងឡើយ។
- យានយន្ត អាចចូលតាមច្រកព្រំដែនមួយ និងចេញតាមច្រកព្រំដែនមួយផ្សេងទៀត ប៉ុន្តែអាចប្រើប្រាស់តែបណ្ដាញផ្លូវដែលមានចែងក្នុងពិធីសារ ១ នៃ CBTA។

# អនុលោមភាពក្នុងប្រទេស "ម្ចាស់ផ្ទះ" (បន្ត)

- នៅពេលប្រកាសបើកឱ្យប្រើប្រាស់ សាធារណៈរដ្ឋប្រជាមានិតឡាវ នឹងបើកខ្សែផ្លូវជាតិលេខ៣ និង ៩ ចេញពី Houayxay ទៅ Boten និងពី Savannakhet ទៅ Dansavanh ហើយរួមទាំង ផ្លូវជាតិលេខ១៣ ពី Boten ពី Nong Nok Khiene។
- កិច្ចព្រមព្រៀងទ្វេភាគី កំពុងត្រូវបានចរចារជាមួយប្រទេសមីយ៉ាន់ម៉ា។
- យានយន្ត ត្រូវអនុលោមតាមបទដ្ឋានបច្ចេកទេសលើកម្រិតទម្ងន់កំណត់ បន្ទុកអ័ក្ស និងវិមាត្រដែលសមស្របតាមបណ្តាញផ្លូវនៃប្រទេសជាម្ចាស់ផ្ទះ សម្រាប់ផែនការដឹកជញ្ជូនរបស់ពួកគេ (ដែលរួមមាន បណ្តាប្រទេសជាសមាជិក GMS មួយចំនួន)។
- ផ្លូវ និងបន្ទុក ត្រូវមានការរៀបផែនការតាមលក្ខខណ្ឌទុកជាមុន ពីព្រោះការខកខានមិនគោរពតាមបទបញ្ញត្តិ (ចាំបាច់ត្រូវរក្សាគុណភាពបណ្តាញផ្លូវ CBTA) ត្រូវប្រឈមនឹងការលុបចោលលិខិតអនុញ្ញាត និងការដកឈ្មោះប្រតិបត្តិករពី 'Early Harvest' ។

# អនុលោមភាពក្នុងប្រទេស “ម្ចាស់ផ្ទះ” (បន្ត)

- នៅពេលឆ្លងកាត់ ការលើក ឬដាក់ទំនិញ ឬអ្នកដំណើរ នៅតាមទីតាំងលើបណ្តាញផ្លូវ CBTA (ដូចមានរាយនាមនៅក្នុងពិធីសារ ១ នៃ CBTA) ប្រតិបត្តិករ នឹងត្រូវបានផ្តល់សិទ្ធិដូចគ្នាទៅនឹងយានយន្តក្នុងស្រុកដែលមានប្រភេទ និងបន្ទុកដូចគ្នា។
- សិទ្ធិដឹកជញ្ជូន (រួមមាន ការលើក និងដាក់ទំនិញ និងអ្នកដំណើរ នៅក្នុងប្រទេសជាម្ចាស់ផ្ទះតែមួយ) មិនត្រូវបានអនុញ្ញាតឡើយ ដោយហេតុ ប្រតិបត្តិការ ‘Early Harvest’ ត្រូវតែជា ‘ការឆ្លងកាត់ព្រំដែន’។
- ការយកចិត្តទុកដាក់ និងប្រុងប្រយ័ត្ន ត្រូវប្រកាន់ខ្ជាប់ជានិច្ច ចំពោះការកំណត់កម្រិតល្បឿនសញ្ញាចរាចរ និងគោលការណ៍សុវត្ថិភាពផ្លូវជាទូទៅ ដែលរួមទាំងការអនុវត្តចំពោះយានយន្តចង្កូតឆ្វេង ដែលកំពុងបើកបរលើគន្លងផ្លូវប្រកាន់ស្តាំ (និងផ្ទុយពីនេះ) ។
- យានយន្តទាំងឡាយ ត្រូវមានភ្ជាប់សេវាធានារ៉ាប់រងពីភាគីទីបីដែលមានសុពលភាពគ្រប់ពេល។

# អនុលោមភាពក្នុងប្រទេស “ម្ចាស់ផ្ទះ” (បន្ត)

- ទំនិញដឹកជញ្ជូន នឹងត្រូវបន្តគោរពតាមនីតិវិធីគយក្នុងស្រុក (ពោលគឺ ការផ្តល់ឧបសម្ព័ន្ធ ៦ នៃ CBTA ស្តីពីប្រព័ន្ធអនុតំបន់ស្តីពីការដឹកឆ្លងកាត់ និងដឹកក្នុងស្រុក នឹងមិនអនុវត្តចំពោះ “Early Harvest” ឡើយ)។

- នៅពេលមានករណីបែបនេះ ប្រតិបត្តិករត្រូវប្រើប្រាស់ប្រព័ន្ធ (ឧ. ជាតិ) ផ្សេងទៀត ចំពោះចរាចរទំនិញឆ្លងកាត់(គយ) ដែលស្របតាមការអនុវត្តបច្ចុប្បន្ន។

- មិនមានការទាមទារការធានាផ្នែកហិរញ្ញវត្ថុ (មូលបត្រគយ) ចំពោះការបម្លាស់ទីយានយន្ត និងកុងតឺន័រ ដូចមានចែងក្នុងអនុស្សរណៈយោគយល់ ‘Early Harvest’ និងតាមលក្ខណៈប្រការ ១៨ នៃ CBTA ។

- មន្ត្រីគយនៃប្រទេសជាម្ចាស់ផ្ទះ នៅតាមច្រកព្រំដែននៃពិធីសារ ១ នឹងធ្វើការត្រួតពិនិត្យលិខិតអនុញ្ញាត Permits និង TADs ដោយត្រូវបោះត្រា និងចុះកាលបរិច្ឆេទលើ TADs របស់យានយន្តបរទេស នៅរាល់ពេលចេញ និងចូល។

- ព័ត៌មានលម្អិតបន្ថែមអំពី CBTA 'Early Harvest' រួមទាំងអត្ថបទនៃ អនុស្សរណៈយោគយល់ 'Early Harvest' ដែលបានចុះហត្ថលេខា ច្បាប់ចម្លងគំរូនៃលិខិតអនុញ្ញាត (Permits) និង ឯកសារអនុញ្ញាតិចូលបណ្តោះអាសន្ន (TADs) និង ច្បាប់ចម្លងនៃខិត្តប័ណ្ណ 'Early Harvest' មាននៅលើគេហទំព័រ [www.greattermekong.org/ttf](http://www.greattermekong.org/ttf) ។

សូមអរគុណ!

បង្កើតឡើងក្រោមគម្រោងជំនួយបច្ចេកទេសលេខ TA 6579-REG ៖ ការអនុវត្តកិច្ចព្រមព្រៀងសម្របសម្រួលការដឹកជញ្ជូនឆ្លងកាត់ព្រំដែន «ដំណាក់កាលប្រមូលផលដំហានដំបូង» ក្នុងមហាអនុតំបន់ទន្លេមេគង្គ
តាមរយៈសហហិរញ្ញប្បទាន ដោយ រដ្ឋាភិបាលនៃចក្រភពអង់គ្លេស